# ការសម្ភាសរបស់ ម៉ី សុគន្ធារី

កៈ អ្នកសម្ភាស (ឡេង ភក្តី) ខៈម៉ី សុគន្ធារី

កៈ ឥឡូវខ្ញុំចង់សួរឈ្មោះពេញរបស់អ្នកមីងមានឈ្មោះអីខ្លះដែរតាម តាមអត្តសញ្ញាណប័ណ្ណ?

ខៈ ឈ្មោះនូវពីតូចហ្ន៎?

ខៈ អត់ទេ!ឈ្មោះតាមអត្តសញ្ញាណប័ណ្ណ?

ខៈ ឈ្មោះខ្ញុំតាមអត្តសញ្ញាណប័ណ្ណគឺ ម៉ី សុគន្ធារី។

កៈ ម៉ី សុគន្ធារីណ៎! ហើយចុះអ្នកមីងគេហៅ ធម្មតាគេហៅឈ្មោះអីដែរ?ឈ្មោះគេហៅហ្ន៎?

ខៈ ឈ្មោះគេហៅឈ្មោះ អឺ...ពេលចូលសាសនាចក្រដាក់ឈ្មោះផ្សេង។

កៈ អត់ទេឈ្មោះគេហៅនៅផ្ទះឈ្មោះអីដែរ?

ខៈ គេហៅថាណារី

កៈ ឈ្មោះណារីណ៎! មានឈ្មោះហៅក្រៅអីទៀតទេណ៎?

ខៈ ឈ្មោះហៅក្រៅនៅតូចឈ្មោះថារី។

កៈ នៅតូចឈ្មោះថារី ណ៎?

ខៈ ហឺ...អត្តសញ្ញាប័ណ្ណឈ្មោះ ម៉ី សុគន្ធារី។

កៈ អូខេ!

ខៈ ហើយពេលចូលសាលនាចក្រឈ្មោះ ម៉ី សុណារី។

កៈ ហើយចុះអ្នកមីង... អឺ...មានរៀនភាសាអីក្រៅពីភាសាខ្មែរអត់?

ខៈ អត់បានរៀនផងទាំងពីតូចមក។

កៈ អូ៎អញ្ចឹងហ្ន៎ហើយចុះអ្នកមីងចេះអាន សរសេរអក្សរខ្មែរហ្មែ៎?

ខៈ ចេះសរសេរតិចតួច.....

កៈ អញ្ចឹងហ្ន៎? អូខេ! ហើយអ្នកមីងដូចជាមានស្រុកកំណើតនៅឯណាដែរ?

ខៈ ស្រុកកំណើតនៅខេត្តព្រៃវែង

កៈ ភូមិ?

ខៈ ភូមិល្វា ឃុំល្វា ស្រុកកំពង់ត្របែក

កៈ ខេត្តព្រៃវែង?

ខៈ ខេត្តព្រៃវែង... ភូមិល្វា ឃុំល្វា ស្រុកព្រះស្តេច ខេត្តព្រៃវែង។

កៈ ហើយអ្នកមីងកើតនៅឆ្នាំណាដែរ?

ខៈ កើតនៅឆ្នាំណាផង!ព្រោះអីបែក៧៥(សម័យប៉ុលពតនៅ១៩៧៥) អាយុ៧ឆ្នាំ។

កៈអូខេ...អញ្ចឹងចាំមើលអត្តសញ្ញប័ណ្ណ?

ខៈ អត្តសញ្ញប័ណ្ណដាក់ស្ថានហ្នឹង!

កៈ អត់អីទេអញ្ចឹង!

កៈ ហើយតាមឆ្នាំប៉ុន្មានដែរដែលអ្នកមីងរៀបការ?

ខៈ ២០០៧

កៈ ២០០៧ ណំ? ហើយនៅពេលហ្នឹងឳពុកម្តាយមីងជាអ្នករៀបចំឲ្យឬយ៉ាងម៉េច?

ខៈដូចជាក្រុមជុំនំ។

កៈ ក្រុមជុំនំអ្នករៀចចំឲ្យណំ! ហើយមួយទៀតតើអ្នកមីងមានបងប្អូនប្រុសស្រីប៉ុន្មាននាក់ដែរ?

ខៈ បងប្អូនមាន៥នាក់ ប្រុស៣ ស្រីមីងមួយហ្នឹង។

កៈ ហើយអ្នកមីងកូនទីម៉ានដែរ?

ខៈ ខ្ញុំជាកូនទី៥។

កៈ កូនពៅគេណំ! ហើយចុះបងប្អូនហ្នឹងប្រាប់មួយៗគាត់មានអាយុប៉ុន្មានដែរ?

ខៈ បង..បងគេបង្អស់ប៉ុលពតសម្លាប់មិនដឹងអាយុប៉ុន្មានទេ!បែក៧៥មិនដឹងមានមានម៉ែអីប្រាប់ផង។ ហើយបន្ទាប់មកបងទី២ ប្រហែលជាអាយុ៥០យីយ៉ាង។

កៈ គាត់នៅរស់សព្វថ្ងៃ?

ខៈ គាត់នៅរស់ នៅមណ្ឌលគីរី។ហើយមួយទៀត(បងទី៣) ប៉ាសុខនីនបានស្លាប់ដោយសារជម្ងឺទៀចទឹក។

កៈ បន្ទាប់មកបានអ្នកមីងណំ?

ខៈ ចាស៎!

កៈ ហើយដូចជាអ្នកមីងអាចប្រាប់ខ្ញុំបានតិចតួចអំពីពួកគាត់ គាត់ចូលចិត្តធ្វើអីកាលនៅតូចលេងជាមួយគ្នាយ៉ាងម៉េច ជាមួយបងប្អូនហ្នឹង?

ខៈ ពួកគាត់ចូលចិត្តទាត់បាល់ និងហ្ន៎...ហ្ន៎...គាត់ចូលចិត្តលេងទាត់បាល់ អត់សូវចូលចិត្តសិក្សា ហើយមីងចូលចិត្តសិក្សា។

កៈ ហើយអញ្ចេក តើអ្នកមីងមានដឹងឳពុកម្តាយរបស់អ្នកមីងហ្នឹងគាត់កើតនៅណាអត់?

ខៈ អើយ...ម៉ាក់...ម៉ាក់របស់មីងគាត់កូនកំព្រាប៉ុន្តែស្រុកកំណើតគាត់នៅបាត់ដំបង។ ម្តាយហ្នាស់!

កៈ ម្តាយ គាត់ឈ្មោះអ្វីដែរ?

ខៈ គាត់ឈ្មោះលូន អួន ហើយឳពុកកើតនៅព្រៃវែង គាត់ឈ្មោះអ៊ូយ ជា

កៈ ហើយសព្វថ្ងៃគាត់មានអាយុប៉ុន្មានហើយ?

ខៈ អត់ដឹងដែរ គាត់បែក៧៥ កាលនៅពីតូច អត់ដឹងអាយុប៉ុន្មាន? គាត់ស្លាប់នៅនា? បើឳពុកដឹងថាគាត់ឈឺជម្ងឺលើសឈាម គាត់ស្លាប់ឆ្នាំ១៩៨៣ ម្តាយបែក៧៥ អត់ដឹងស្លាប់ឬរស់ទេ?

កៈ អញ្ចឹងមានន័យថាអង្គាល់ខ្មែរក្រហមវាយបែកទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥ គាត់រត់ចេញពីភ្នំពេញទៅក៏បាត់ពីម្ដាយទៅអត់ដឹងគាត់ទៅណាទេ?

ខៈ  ចាស់រហូតដល់សព្វថ្ងៃនេះ។ អត់ដឹងស្លាប់ឬក៏រស់ទេ។

កៈ ហើយអ្នកមីងមានដឹងថាឳពុកម្ដាយរបស់អ្នកមីងកើតឆ្នាំអ្វីទេ?

ខៈ  អត់ដឹងផងព្រោះយើងនៅតូចហើយសម័យប៉ុលពតជម្លាសចេញយើងបែកក្រុមគ្រួសារអស់ អត់ដឹងថាប្រវត្តិម៉េចផង!

កៈ ហើយមួយទៀតអ្នកមីង ហ្ន៎អ្នកមីងមានចាំថាលោកតាលោកយាយរបស់អ្នកមីង មានឈ្មោះអីខ្លះដែរ?

ខៈ ថាម៉េច?

កៈ លោកតាលោកយាយមានឈ្មោះអីខ្លះដែរ?

ខៈ លោកតាឈ្មោះ...

កៈ លោកតាខាងណាដែរ?

ខៈ លោកតាខាងម៉ាក់ ដូចអត់ដឹងប្រវត្តិព្រោះអីគាត់កូនកំព្រា ម៉ែឪខាងប៉ាគាត់ឈ្មោះ គួយ យា ហ្ន៎... អ៉ា.....ស្អីទេ?... អឺ... ឈ្មោះស្អីគួយហ្មែ៎... មុី គួយ ហើយប្រពន្ធគាត់ឈ្មោះអឺ...យាយ មុី ប្រពន្ធ២ ហ្នស់ យាយមុី ហើយ យាយសួន

.កៈ តាមខាងឪពុក អឺ...អូ៎!មួយទៀតទាក់ទងនឹងស្រុកកំណើតរបស់ឪពុកម្ដាយរបស់អ្នកមីង តើអ្នកមីងស្គាល់ដេស់? ឪពុកម្ដាយរបស់អ្នកមីង ហ្នា៎?

ខៈ  អូនែ! ម៉ាក់គាត់កើតនៅបាត់ដំបង ស្រុកកំណើតនៅបាត់ដំបង ដឹងតែខេត្តបាត់ដំបង....

កៈ អូខេ!បន្តទៅទៀតហើយដូចជាអញ្ចេះអ្នកមីងមានដឹងថាក្រុមគ្រួសាររបស់អ្នកមីងហ្នឹង ដែលមានឪពុកនិងម្ដាយហ្នឹងកាលនៅក្មេងគាត់រស់នៅស្រុកខ្មែរហ្នឹងតាំងពីពួកគាត់កើតតែងម្ដង?

ខៈ ហ្នឹងហើយតាំងពីកើតមកម៉េស។

កៈ ចឹងគាត់ដល់ពេលអ្នកមីងធំឡើងដឹងក្ដីនៅខេត្តណាដែរ?

ខៈ កាលពមីងកើតនៅភ្នំពេញហ្មែ៎ តែដល់ពេលជម្លៀសទៅនៅខេត្តព្រៃវែង។

កៈ ព្រៃវែង ហ្ន៎ះ?

ខៈ អឺម!

កៈ ហើយដូចជានៅពេលហ្នឹងស្ថានភាពនៅខេត្តព្រៃវែងយ៉ាងម៉េចដែរ?

ខៈ ជម្លៀសទៅពេលនៅពល់ពតហ្នឹងហ្ន?

កៈ ហ្នឹងហើយ!

ខៈ  ដូចជាពិបាកខ្លាំង វាអត់សូវមាន អឺ...អាហារទទួលទានអញ្ចឹងទៅណ៎ា! ហ្នឹងហើយ ការគាបសង្កត់ក៏វាមានតិចតួចទេ ក៏ប៉ុន្តែអាហារអត់ខ្លាំង។

កៈ នៅជំនាន់ខ្មែរក្រហម អ្នកមីងដឹងក្ដីឡើងនៅជំនាន់ខ្មែរក្រហមហ្នឹង?

ខ៖ ហ្នឹងហើយ!

កៈ ហើយដូចជានៅពេល ហ្នឹងដូចជាមានគេសម្លាប់មនុស្សអីទេ?អ្នកមីងឃើញពេលហ្នឹង?

ខ៖ អត់ឃើញផង!
គ្រាន់ថាបងប្អូនសាច់ញាតិយើងអញ្ចឹងដូចជាពួកវាត្រូវគេយកទៅវាយចោល។បងប្អូន...
បងប្អូនដូចជាពូធ្វើប៉េអឹម(ទាហាន)នៅកាម៉ុងដូ(ឈ្មោះកន្លែងកងទ័ព)នៅសម័យសង្គមរាស្ត្រនិយមត្រូវគេវ៉ៃយចោលអស់ទៅ ហើយអត់ឃើញគាត់ស្លាប់ទេណា ប៉ុនតែបាត់មនុស្សអស់ម៉ង
បាត់អស់រលីងតែម្តង។

កៈ ចុះកាលហ្នឹងអ្នកមីងមានដឹងថាគេយកទៅសម្លាប់អីដេស ក៏អត់ដឹងទេព្រោះនៅក្មេងពេក?

ខ៖ អត់ដឹងទេ ដឹងតែគេយកពូទៅបាត់តែម្តង។ តែមានអ៊ុំមកវិញបាន គាត់ឈ្មោះ វ៉ានណា
ឥឡូវគាត់នៅអាមេរិក។ គាត់ធ្វើកាម៉ុងដូ។

កៈ ហើយអញ្ចេកចង់សួរថា អ្នកមីងធ្លាប់ទៅរៀនកាលនៅពីក្មេងធ្លាប់ទៅរៀនដល់ថ្នាក់ទីប៉ុន្មានដែរ?

ខ៖ អង្កាល់ឆ្នាំ ៧៩ឆ្នាំ៨០ ចូលរៀនបាន៨០-៨១ចូលរៀនបានថ្នាក់ទី១ រៀបចូលថ្នាក់ទី២
ឪពុកស្លាប់ចោល ហើយក៏អត់បានរៀនមកដល់សព្វថ្ងៃ។

កៈ ហើយកាលនោះសាលានោះមានឈ្មោះអ្វីដែរ?

ខ៖ កាលនោះសាលាមានឈ្មោះថា កម្ពុជាបុត្រ

កៈ តើសាលានោះនៅឯណាដែរ? នៅខាងក្រោយមេភ្លើងនៅឯណាដែរ?

ខ៖ នៅភ្នំពេញនឹង ម៉្តុំ វានៅម្តុំពេទ្យចិន សាលាពីសង្គម

កៈ ហើយទៀតថា អ្នកមីងថាមុខរបរធ្លាប់ធ្វើជចម្ការ ឬក៏មានធ្លាប់ប្រកបមុខរបររកស៊ីអីទេ?

ខ៖ អត់ធ្លាប់ធ្វើចម្ការអីផង។

កៈ អញ្ចឹងធ្លាប់ធ្វើអី?

ខ៖ អត់ដែរផង។

កៈ រកស៊ី?

ខ៖ ដូចជាធ្លាប់ធ្វើការអត់ពិតប្រាកដអញ្ចឹង។ ធ្វើការ....តាមសណ្ឋាគា តាមអីអញ្ចឹង តាមក្រុមហ៊ុន
ការងារតាមផ្ទះអីអញ្ចឹងទៅណា។

កៈ ការងារសម្អាតហ្មេ?

ខ៖ ហ្នឹងហើយ ដោយសារយើងអត់បានរៀនសូត្រអីចឹងហ្មា។

កៈ អញ្ចេក! អ្នកមីងគិតកាលដែលសម័យឥឡូវ កាលដែលអ្នកមីងនៅក្មេង ហើយមកដល់ឥឡូវ
មានការខុសប្លែកយ៉ាងម៉េចដែរ?

ខ៖ កាលពីអាយុ៧ឆ្នាំ ធ្លាប់មានការលំបាកច្រើន រហូតដល់ឪពុកស្លាប់ក៏នៅតែលំបាកខ្លាំងដែរ
នៅតែលំបាករហូតដល់មានគ្រួសារ ទើបបានធូរធារជាងមុន គ្រាន់បើជាងកាលស្គាល់សាសនាចក្រ
បានធូរធារទាំងខាងព្រលឹងវិញ្ញាណ និងខាងរូបកាយ រហូតដល់សព្វថ្ងៃហ្នឹងជីវភាពអ្វីក៏មិនសូវ
លំបាកដូចមុនពេលយើងមិនទាន់ស្គាល់ព្រះ។

កះ ហើយអញ្ចេក អ្នកមីងកាលនៅ អ្នកចូលចិត្ត ដូចជាចូលចិត្តធ្វើអីដែរ?

ខះ មានចំណង់ចំណូលចិត្តចង់ដើរសួរសុខទុក្ខសមាជិក ព្រោះគ្មានពេលដើរលេងស្គាល់ខេត្តណាផង។

កះ ចុះពេលតើមីងមានមុខម្ហូបណាដែលអ្នកមីងចូលចិត្តទេ?មានម្ហូបដែលចូលចិត្ត មានអ្វីខ្លះដែរ?

ខះ  ចូលចិត្ត ដូចជាចូលចិត្តទាំងអស់។

កះ មើលសុំរើសយកអាណាមួយដែលមីងចូលចិត្តខ្លាំង?

ខះ មើលចូលចិត្តស្ងោរជ្រក់ក្បាលត្រី សម្លរកកូរត្រីចៀនអីនឹង ឆាឡុកឡាក់អ្វីនឹង អាហ្នឹងចូលចិត្ត។

កះ តើមីងរៀនធ្វើម្ហូបពីនរណាគេដែរ? នរណាគេប្រាប់?

ខះ ដូចជាអត់បានរៀនពីនរណាគេផង។ ដូចជារៀន និងស្មានខ្លួនឯង។

កះ ដូចជាធ្លាប់មើលគេពីមុនដែរ បានធ្វើកើត?

ខះ ឃើញគេធ្វើ ប៉ុន្តែអត់មានយកចិត្តទុកដាក់ធ្វើម៉េចអញ្ចឹងណា។ យើងមើលគេអាចជួយឲ្យម្ហូបឆ្ងាញ់ផងដែរដោយសារគេមានរូបមន្តរបស់គេ។ តែមីងចេះតែដាក់ខ្លួងឯង ផ្សំគ្រឿងខ្លួងឯង មិនសូវឆ្ងាញ់

កះ កាលមីងនៅតូច មីងចូលចិត្តស្តាប់ចម្រៀងអីដែរ?

ខះ ចូលចិត្តស្តាប់ចម្រៀងពីដើម ដូចជាលោកស៊ិន ស៊ីសាមុត អ្នកស្រី រស់ សេរីសុធា។

កះ ហើយនៅក្នុងសមាជិកគ្រួសារ អ្នកមីងមាននរណាចេះច្រៀងឬលេងភ្លេងអីដែរទេ?

ខះ  ដូចជាអត់ឃើញមានផង។ ហើយសួរចុះផ្ទះអ្នកមីងកាលដែលនៅក្មេងយ៉ាងម៉េចដែរ?
នៅឆ្នាំ១៩៧០-៨០ មានផ្ទះនៅ តែនៅផ្សារស៊ីឡិប។

កះ ផ្ទះនឹងជាផ្ទះថ្ម ឬក៏ផ្ទះឈើ?

ខះ  ផ្ទះថ្ម ផ្ទះឡើងមានច្រើន យើងចង់ចាប់ទុកក៏បានដែរ ព្រោះផ្ទះមានទាំងជុងៗ
មានតែហៅឲ្យគេមកនៅ។ ពេលឪពុកស្លាប់ទៅគេក៏យកផ្ទះអស់ទៅ។
កាលនោះនៅតូចពេកអត់ចេះថែទាំ។

កះអញ្ចឹងផ្ទះហ្នឹងពេលខ្មែរក្រហមចប់ទៅប្រជាជនខ្មែរបានចូលមកភ្នំពេញហើយឃើញផ្ទះដែលគេសាងសង់ច្រើន ហើយយើងចូលទៅរស់នៅ។

ខះ នៅផ្ទះសល់ពីសម័យសង្គមរបស់ជ័យសោភ័ណ្ឌ។ ពេលយើងចូលមក យើងចូលមកនៅ
ព្រោះថាម្ចាស់ផ្ទះគេស្លាប់នៅសម័យប៉ុលពតអស់ហើយ។ ហើយយើងចាប់យក
ចាប់យកឲ្យអ្នកអត់ឲ្យគេនៅអញ្ចឹងទៅ គេនៅម៉ាកានរនាក់ហ្នឹង មិនខ្វះទេផ្ទះ។ ចែកឲ្យគេមកនៅ។
ប៉ុន្តែតាណាចាក់សោទុកឲ្យកូនគាត់នៅ ប៉ុន្តែពេលគាត់ស្លាប់ទៅ គេក៏មកនៅអស់ទៅ។
យើងនៅកូនយើងអត់ចេះថែទាំផ្ទះអស់ហ្នឹង។

កះ ហើយមួយទៀតតើអ្នកមីងមានចេះជំនាញអ្វីផ្សេងៗទៀងអត់? ដូចជាចេះធ្វើស្ករត្នោត
ត្បាញរវៃអ្វីទេ?

ខះ អត់ចេះទេ ចេះតែដាល់អំបុក។

ចេះតែធ្វើអំបុកទេ។

កះ អាមួយហ្នឹងក៏ជាជំនាញមួយផងដែរ! ឥឡូវនឹងលែងដាល់អំបុកទៀតហើយ?

ខ៖ ខ្សោយអស់ហើយកាលនៅក្មេងអាចដាល់អំបុកបាន

ក៖ តើដាល់អំបុកគេធ្វើម៉េចដែរ?

ខ៖ គេលីងឲ្យវាផ្ទុះ ហើយដាល់មនុស្សពីរនាក់ទៅ។ អ្នកខ្លះដាល់ អ្នកខ្លះទៀតផ្អៀលអំបុកទៅ ហើយយើងយើងអត់ផ្អៀល យើងបុកអំបុកទៅ។

ក៖អញ្ចឹងអ្នកផ្អៀស ចាំតែផ្អៀសទៅ អ្នកបុកអំបុកចាំតែបុកអំបុកទៅ។

ខ៖ ជំនាន់ទើបតែបែកហ្នឹង ដាល់អំបុកហ្នឹងសប្បាយខ្លាំងណាស់ ដូចជាហាត់ប្រាណអញ្ចឹង។

ក៖ មួយទៀត
អ្នកមីងសូមជួយប្រាប់ខ្ញុំមើលតើពេលណាក្នុងជីវិតរបស់អ្នកមីងដែលពិបាកជាងគេ?ថាអ្នកមីងឆ្លងកាត់វាយ៉ាងម៉េចដែរ?

ខ៖ ពិបាកជាងគេគឺនៅពេលដែលឪពុកទើបតែស្លាប់ភ្លាមៗ ពិបាករហូតដើរទៅរស់នៅជាមួយគេ។

ក៖ ពិបាកយ៉ាងម៉េចដែរ?

ខ៖ ដើរនៅជាមួយគេ គ្មានភាពកក់ក្ដៅ ឯកោអញ្ចឹងអត់បានរៀនសូត្រ គិតតែពីនឹកឪពុកម្ដាយ។ អត់បានរៀនអញ្ចឹង ពិបាក! ពិបាកហ្នឹងនិយាយថាយ៉ាងម៉េចទេ បើវាមានភាពលំបាកច្រើនពេក។ រៀបរាប់មិនចង់អស់។ នៅជាមួយគេរហូតគេឲ្យលក់ជំឡូង លក់ពោត ដើម្បីដូរបាយញុាំ ឲ្យតែមានបាយហូប អញ្ចឹងហ្នា! រហូតបានមកធ្វើការមានប្រាក់ខែខ្លួនឯង ប៉ុន្តែនៅជាមួយ ពួកគេយកប្រាក់ចំណេញ បោកខោអាវ និងមើលកូនឱ្យគេរហូតតែមានការងារមានប្រាក់ខែ មានការងារខ្លួនឯង ចេះជួលផ្ទះនៅខ្លួនឯង ចេះដោះស្រាយបញ្ហាខ្លួនឯង។ប៉ុន្តែនៅតែពិបាករហូត ណាមួយដោះស្រាយថ្លៃជួលផ្ទះ។

ក៖ ពេលណាដែលអ្នកមីងសប្បាយជាងគេនៅក្នុងជីវិត?

ខ៖ ពេលសប្បាយចិត្តជាងគេគឺនៅពេលដែលយើងមានគ្រួសារ មានភាពកក់ក្ដៅ មានកម្លាំងចិត្តពីគ្រួសារយើង  ពេលស្គាល់ដំណឹងល្អជីវិតយើងជៀសផុតពីសេចក្ដីលំបាក ទោះបីយើងលំបាកប៉ុណ្ណាក៏យើងនៅតែសប្បាយដែរ ដោយសារយើងស្គាល់ដំណឹងល្អ ស្គាល់ព្រះមកគឺសប្បាយរហូត ទោះបីមានទុក្ខប៉ុណ្ណាក៏ដោយ ការអន់ចិត្ត មានការរងទុក្ខ មានជម្ងឺប៉ុណ្ណាក៏នៅតែមានកម្លាំងចិត្តពីគ្រួសារ និងពីព្រះសិក្ខាបទ។

ក៖ ហើយកាលអ្នកមីងនៅក្មេង តើមានបំណងប្រាថ្នាចង់ធ្វើអ្វីដែរ?

ខ៖ មានចង់ធ្វើដែរ ប៉ុន្តែយើងមិនអាចទៅរួចដោយសារយើងអត់មានជំនាញអីមួយ ក៏មិនបានសម្រេចទៅ។

អ្នកសម្ភាស៖ ចុះកាលហ្នឹងអ្នកមីងចង់ធ្វើអីដែរ?

ខ៖ ដូចចង់តែរៀន អាចង់ធ្វើការនៅការិយាល័យអញ្ចឹងដែរ។ហើយនៅជំនាន់នោះដូចចង់ច្រៀង ប៉ុន្តែយើងមិនអាចធ្វើទៅរួច។

ក៖ អញ្ចឹងអ្នកមីងចង់ធ្វើតារាចម្រៀង?

ខ៖  ចង់ធ្វើតារាចម្រៀង ប៉ុន្តែសម្លេងអត់សូវពិរោះ។

ក៖ អញ្ចឹងអរគុណអ្នកមីងច្រើនសម្រាប់ការធ្វើការសម្ភាសហ្នឹង ប្រហែលជាខ្ញុំនឹងថតរូបអ្នកមីងខ្លះៗ។
<......>

ខ៖ ការសម្ភាសនេះជាពាក្យពិត អត់បន្លំទេ។

ក៖ អញ្ចឹងខ្ញុំនឹងថតរូបអ្នកមីងយើងផ្ញើរការសម្ភាសនេះទៅសកលវិទ្យាល័យBYU។ ដើម្បីដាក់ក្នុងវេបសាយបានទេ។ អញ្ចឹង អូខេ!

ខ៖ ចាស់! អូខេ!

ក៖ អញ្ចឹង សូមអរគុណច្រើន!

ខ៖ អរគុណ!

Taggs:

*Name:*

Mey Sokuntheary, ម៉ី សុគន្ធារី

*Gender:*

Female

*Date of Interview:*

?

*Location of Interview:*

Prei Veng, ព្រៃវែង

*Marriage Status:*

Traditional

*Place of Birth:*

Rovea, Rovea, Preah Sdech, Prei Veng

ភូមិរវា, ឃុំរវា, ស្រុកព្រះស្តេច, ខេត្តព្រៃវែង

*Age:*

Age: 49

Year: 1968 ( ? )

Era:

Zodiac Year: ( figure out the year )

*Primary Language and Secondary Language:*

Primary: Khmer

Secondary: None

*Ethnicity:*

Khmer

*Family Size:*

6

*Family Religious Background*

Background: Buddhist

Current: Latter-day Saint

*Refugee ( Yes/No )*

No